**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..១០៣..អនក្រ**

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើត អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **សុខត្ថិ សុក្រិត្យា** អត្តលេខ ០១៩៧៥៣ ជា នាយការិយាល័យ អនុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី ជំនួស ឧត្តមសេនីយ៍ត្រី អៀង លីសក្តិ ដែលត្រូវចប់អាណត្តិ

២-វរសេនីយ៍ទោ **ឡៀម ទិរៈ** អត្តលេខ ០២៥១០៤ ជា នាយរងការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានកុងស៊ុលព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួស វរសេនីយ៍ឯក យ៉ង់ វុឌ្ឍី ដែលត្រូវចប់អាណត្តិ

៣-វរសេនីយ៍ទោ **ឈឺន នារិយ** អត្តលេខ ០៤៣៤៨៥ ជា ជំនួយការរដ្ឋបាល និងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ជំនួស វរសេនីយ៍ទោ ហាម យឹម ដែលត្រូវចប់អាណត្តិ

www.pheakdeylaw.com

៤-វរសេនីយ៍ទោ **ម៉ម សីហា** អត្តលេខ ០៥៨៤៨១ ជា ជំនួយការរដ្ឋបាល និងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធាអមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី ជំនួស វរសេនីយ៍ទោ ហ៊ួន ចំរើន ដែលត្រូវទទួលភារកិច្ចថ្មី

៥-វរសេនីយ៍ទោ **ហ៊ួន ចំរើន** អត្តលេខ ១០០៧៩១ ជា ជំនួយការរដ្ឋបាល និងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធាអមស្ថានបេសកកម្ម អចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ជំនួស វរសេនីយ៍ទោ ណុប ប៊ុនថង ដែល ត្រូវចប់អាណត្តិ

**ប្រការ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com